# ប្រភេទសហគមន៍ព្រៃឈើនៅប្រទេសកម្ពុជា និងបណ្ដាប្រទេសមួយចំនួន

**<u>ទស្សនៈទូទៅ</u> :**

កម្ពុជា ជាប្រទេសមួយដែលរងនូវសង្គ្រាមជាងពីរទសវត្សមកហើយ និងការធ្វើផែនការដោយមជ្ឈមណ្ឌលជាអ្នកកំនត់ បណ្ដាលអោយមានការបាត់បង់ប្រយោជន៍លើវិស័យព្រៃឈើ និងប្រភពធនធានធម្មជាតិដទៃទៀត ។ ទស្សនៈនៃការគ្រប់គ្រងដោយសហគមន៍ គឺជាគំនិតថ្មីមួយ ដែលតាមការមើលឃើញចំណែកខ្លះៗឋិតនៅក្នុងក្ដីមន្ទិលសង្ស័យនៅឡើយ ។ តែទោះជាយ៉ាងណាក៏ដោយក៏វាមានភាពប្រត្យក្សមួយ ដែលថាការត្រួតពិនិត្យ ការការពារព្រៃឈើដោយរដ្ឋពីអតីតមិនបានទទួលជោគជ័យដ៏ល្អប្រសើរនោះទេ ។ ដូច្នេះហើយដីព្រៃរិចរិលជាច្រើនកន្លែងដែលគ្រប់គ្រងដោយរុក្ខាប្រមាញ់ បានទទួលការអនុញ្ញាតអោយធ្វើការគ្រប់គ្រងដោយសហគមន៍វិញដូចជានៅព្រៃលើស្រុក ត្រាំកក់ ចំការព្រៃស្ទេហ៍ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ព្រៃផើងភ្លើង ស្រុកបាកាន ខេត្តពោធិសាត់ ព្រៃខ្លែងពណ៌ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ព្រៃលិចទឹក ស្រុកសូទ្រនិគម ខេត្តសៀមរាប និងព្រៃយ៉ាពយ ស្រុកអូរជុំ ខេត្តរតនគិរី ។

ការងារសហគមន៍ព្រៃឈើត្រូវបានកំណត់ថា ជាមធ្យោបាយដោះស្រាយតំរង់ទិសសង្គមទាំងគោលដៅ និងទាំងការអនុវត្តក្នុងការគ្រប់គ្រងដីព្រៃឈើ ដែលជាទូទៅមានការពាក់ព័ន្ធដល់សហគមន៍មូលដ្ឋានក៏ដូចជាមូលដ្ឋានគ្រឹះរបស់សហគមន៍មួយ ឬបុគ្គលម្នាក់ៗ ។ ការងារសហគមន៍ព្រៃឈើ បង្កប់អត្ថន័យទាំងទស្សនៈនៃការអភិវឌ្ឍន៍ និងទាំងយុទ្ធសាស្ត្រអនុវត្តប្រកបដោយលទ្ធផល ។ គោលគំនិតនៃសហគមន៍ព្រៃឈើត្រូវបានគេបកស្រាយបានជាច្រើនរបៀបនៅក្នុងបណ្ដាប្រទេសជាច្រើន ដែលប្រជាជនបានការពិភាក្សា និងបកស្រាយពាក្យនេះខុសប្លែកផ្សេងៗពីគ្នា ។ ការប្រែប្រួលនៃពាក្យ " ការងារសហគមន៍ព្រៃឈើ " នេះរួមមានទាំងការគ្រប់គ្រងព្រៃឈើរួម ព្រៃឈើភូមិ ព្រៃឈើសំរាប់កិច្ចអភិវឌ្ឍន៍សហគមន៍ ការចូលរួមការងារព្រៃឈើ និងការងារព្រៃឈើជនបទដទៃៗទៀត ។

ដោយហេតុតែមានលក្ខខ័ណ្ឌផ្សេងៗបើកចំហរ ទាំងធម្មជាតិ ទាំងសង្គមនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង កម្មវិធីការងារសហគមន៍ព្រៃឈើ មានទំរង់ច្រើនរបៀបណាស់ មិនមែនតែមួយបែបទេ ។ ជាការពិតណាស់ថា គំលាំងនៃសហគមន៍ព្រៃឈើ គឺជាបែបផែនគំរូនៃការអភិវឌ្ឍន៍ ដែលផ្សារភ្ជាប់ទៅនឹងការកំណត់មួយដែលអាចបត់បែន និងប្រែប្រួលទៅតាមលក្ខខ័ណ្ឌផ្សេងៗបាន ។ ដូច្នេះដើម្បីការអនុវត្តការងារនេះឱ្យបានត្រឹមត្រូវ ត្រូវយល់ថាការងារសហគមន៍

ព្រៃឈើ គឺជាឧបករណ៍ការងារមួយដែលរមែងតែប្រែប្រួលផ្លាស់ប្តូរដោយខ្លួនឯងទៅតាមលក្ខខ័ណ្ឌមូលដ្ឋាន និងតំរូការនានា ។

មូលដ្ឋានគ្រឹះនៃការងារសហគមន៍ព្រៃឈើ វាជាកិច្ចអភិវឌ្ឍន៍ប្រកបដោយផ្លែផ្កាមួយដែលបានមកពីចំនុចសំខាន់ៗ ដូចខាងក្រោម :

១-ការផ្ទេរសិទ្ធអំណាចនៃការគ្រប់គ្រងធនធានធម្មជាតិ ឱ្យអាជ្ញាធរមូលដ្ឋាន

២-បទបញ្ជាផ្ទៃក្នុង

៣-ការប្តេជ្ញាចិត្តដោយខ្លួនឯង

៤-សិទ្ធិទទួលខុសត្រូវ

៥-ធ្វើការសំរេចចិត្តក្នុងការគ្រប់គ្រង

៦-សុពលភាពនៃចំណេះដឹងរបស់ប្រជាជនក្នុងស្រុក និងបណ្តាស្ថាប័ននានា ។

→ គោលគំនិតសំខាន់ៗ ដ៏មានឥទ្ធិពលទាំងនេះ ក្លាយទៅជាលំនាំការងារនៃការអភិវឌ្ឍន៍បណ្តាធនធានព្រៃឈើ សំរាប់ស្ថាប័នគ្រប់គ្រងថ្មី ដែលក្នុងនោះរួមមានទាំងសហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដីដែលមានភារៈទទួលខុសត្រូវ សហការក្នុងកិច្ចការពារ និងគ្រប់គ្រងធនធានព្រៃឈើនេះ ។

តាមការពិនិត្យរបស់អង្គការ (Pardo 1995 ) ស្តីពីកម្មវិធីសហគមន៍ព្រៃឈើនៅក្នុងប្រទេសនេប៉ាល់ ថៃឡង់ និងហ្វីលីពីននាពេលថ្មីៗនេះគេបានរកឃើញនូវបណ្តាកត្តាសំខាន់ៗទាំង ១២ដែលអាចធ្វើអោយសំរេច ជោគជ័យរបស់គំរោងការងារសហគមន៍ព្រៃឈើពោលគឺ :

១.កំណត់ និងស្គាល់អោយបានច្បាស់ ចំពោះសហគមន៍អ្នកដែលប្រើប្រាស់ព្រៃឈើ

២.កំណត់តំបន់ណាមួយ ដើម្បីរៀបចំគ្រប់គ្រង ដោយគ្មានទំនាស់ដល់សិទ្ធិកាន់កាប់ដីធ្លី

៣.ធានានូវសិទ្ធិកាន់កាប់ ប្រើប្រាស់ធនធាន និងដីធ្លី

៤.ត្រូវមានស្ថាប័នមួយសំរាប់រៀបចំគ្រប់គ្រងធនធានដោយផ្តោតជាហិរញ្ញវត្ថុរបៀបគ្រប់គ្រង និងមានបច្ចេកទេសគ្រប់គ្រាន់ចំពោះការងារនេះ

៥.កិច្ចព្រមព្រៀង និងប្រព័ន្ធសំរាប់បែងចែកផលប្រយោជន៍ និងតំលៃ

៦.អាជ្ញាធរមូលដ្ឋានត្រូវមានសមត្ថភាពពេញលេញប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញអោយគេគោរពតាមសេចក្តីសំរេចរួម ច្បាប់ទំលាប់ និងបទបញ្ញត្តិនានា

៧.ត្រូវទទួលការកំណត់យកគោលដៅនៃការគ្រប់គ្រងជាសកល

៨.អង្គភាពដែលមានលទ្ធភាពគ្រប់គ្រងតាមលក្ខណៈសេដ្ឋកិច្ចឬមានមធ្យោបាយខ្លះ (និរន្តភាពតំរូវឱ្យមានចំណូលស្មើ ឬធំជាងចំណាយ )

៩.ផលប្រយោជន៍ខ្ពស់ក្នុងការគ្រប់គ្រងធនធាន

១០.ផែនការគ្រប់គ្រង ត្រូវឆ្លើយតបទៅនឹងបទដ្ឋានគ្រឹះនៃការគ្រប់គ្រងធនធាន (ពោលគឺ បរិស្ថានល្អ និងមាននិរន្តរភាព )

១១.មធ្យោបាយនៃការត្រួតពិនិត្យ និងការកែតំរូវចន្លោះប្រហោង ឬកំហុសឆ្គងក្នុងផែនការគ្រប់គ្រង

១២.ត្រូវមានកិច្ចសន្យាដ៏មាំទាំពីរដ្ឋាភិបាល និងមានការគាំទ្រដោយផលលក្ខខ័ណ្ឌពីបុគ្គលិកជំនាញរដ្ឋបាល និងបុគ្គលិកបច្ចេកទេសក្នុងមូលដ្ឋាន ។

ចំពោះបណ្ដាចំនុចទាំងអស់នេះ គេសង្កេតឃើញថា ត្រង់ចំនុចការធានាសិទ្ធកាន់កាប់ ឬការប្រើប្រាស់ដីធ្លី គឺជាកត្តាមួយដ៏សំខាន់បំផុតក្នុងការទទួលបាននូវការចូលរួមដំបូង និងជួយគាំទ្រដ៏ថិតថេរពីប្រជាជនមូលដ្ឋាន ក្នុងកិច្ចការពារព្រៃឈើ និងសកម្មភាពស្ដារព្រៃឈើឡើងវិញ ។